# ខ្ញុំសូមសួរអ្នកមួយសំណួរបានទេ



មានអ្នកណាម្នាក់
ធ្លាប់បានយក
ព្រះគម្ពីរមក ហើយ
បង្ហាញដល់អ្នកអំពី
ធ្វើដូចម្ដេចទើបអ្នកអាច
**ដឹងយ៉ាងប្រាកដច្បាស់ថា**
អ្នកនឹងទៅនគរស្ថានសួគ៌ឬទេ ?

ព្រះគម្ពីរបានចែងទុក
ទាំង ដំណឹងអាក្រក់ និង
ដំណឹងល្អ ។
ដំណឹងអាក្រក់ គឺ
ជាអ្វីដែលចែងទុកអំពី
អ្នក ។
ដំណឹងល្អ គឺ
ជាអ្វីដែលចែងទុកអំពី
ព្រះ ។

ឥឡូវសូមមើលពីដំណឹងអាក្រក់ជាមុនសិន...

# ដំណឹងអាក្រក់ទី ១

## យើងរាល់គ្នាជាមនុស្សមានបាប

រ៉ូម ៣:២៣ បានចែងថា " ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ "

" បានធ្វើបាប " មានន័យថា យើងមិនបានល្អឥតខ្ចោះ ។ នៅពេលដែលយើងកុហក មានចិត្តស្អប់នរណាម្នាក់ ចិត្តស្រើបស្រាល ឬក៏និយាយដើមអ្នកដទៃ គឺយើងខ្វះមិនដល់មាត្រដ្ឋានដែលព្រះ ទ្រង់បានកំណត់ទុកមក ។





ឧបមាថា អ្នកនឹងខ្ញុំបាននាំគ្នា
ខំប្រឹងចោលថ្មម្នាក់ម្ដុំ ដើម្បីឲ្យទៅ
ដល់ប៉ូលខាងជើង ។ អ្នកប្រហែល
អាចចោលទៅបានឆ្ងាយជាងខ្ញុំ
ប៉ុន្តែ យើងមិនអាចចោល
ទៅដល់ទីនោះដូចគ្នា ។

ពេលដែលព្រះគម្ពីរចែងថា
“ គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់ ”
គឺមានន័យថា យើងគ្រប់គ្នា
បានខ្វះមិនដល់មាត្រដ្ឋានដែល
ល្អឥតខ្ចោះរបស់ព្រះ ។

ក្នុងចិត្តគំនិត ពាក្យសំដី និង ការប្រព្រឹត្តិ
យើងមិនអាចខំដើម្បីឲ្យល្អឥតខ្ចោះបាន ។

ប៉ុន្តែ ដំណឹងដែលរិតតែអាក្រក់ធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺ...

# ដំណឹងអាក្រក់ទី ២

## ឈ្នួលនៃអំពើបាបគឺជាសេចក្ដីស្លាប់

*រ៉ូម ៦:២៣ បានចែងថា " ដ្បិតឈ្នួលរបស់អំពើបាប
នោះជាសេចក្ដីស្លាប់... "*

ឧបមាថា អ្នកបានធ្វើការឲ្យខ្ញុំ
ហើយខ្ញុំបានបើកប្រាក់ឲ្យអ្នក $ ៥០ ។
ប្រាក់ $ ៥០ នោះជាឈ្នួលនៃការងារអ្នក ។
នោះជាប្រាក់ឈ្នួលដែលអ្នកបានទទួលពីការធ្វើការ ។



ព្រះគម្ពីរបានចែងយ៉ាង
ដូច្នេះថា ដោយការ
ធ្វើបាប យើងត្រូវតែ
ទទួលបានឈ្នួលជា
សេចក្តីស្លាប់ ។
មានន័យថា យើងត្រូវ
ទទួលនូវសេចក្តីស្លាប់
ខាងវិញ្ញាណ ហើយ
ត្រូវដាច់ចេញពីព្រះ
វរបូតអស់កល្បជានិច្ច ។



ដោយសារមិនអាចមានផ្លូវណា
ដើម្បីឲ្យយើងឈោងទៅដល់ព្រះ
ព្រះគម្ពីរបានចែងប្រាប់ថា
ព្រះបានយាងចុះមករកយើងវិញ !

# ដំណឹងល្អទី ១

## ព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា

*រ៉ូម ៥:៨ បានចែងថា “ តែឯព្រះ ទ្រង់សំដែងសេចក្ដីស្រឡាញ់ របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទ បានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅ មានបាបនៅឡើយផង ”*

ឧបមាថា អ្នកជិតស្លាប់ដោយសារជម្ងឺមហារីកនៅឯ មន្ទីរពេទ្យ ។ ខ្ញុំបានមកជួបអ្នកហើយនិយាយថា “ សូមផ្ទេរកោសិកាមហារីកពីក្នុង**ខ្លួនអ្នក** ហើយដាក់វាចូលក្នុង**ខ្លួនខ្ញុំ**ជំនួសវិញ ។ ”

ប្រសិនបើ មានការកើតឡើងយ៉ាងដូច្នេះ

**តើនឹងមានការអ្វីកើតឡើងចំពោះខ្ញុំ ?**

**តើនឹងមានការអ្វីកើតឡើងចំពោះអ្នក ?**

## ខ្ញុំនឹងស្លាប់ហើយ
## អ្នកនឹងរស់ ។
## ខ្ញុំនឹងស្លាប់
## ជំនួសអ្នក ។



ព្រះគម្ពីរបានចែងថា ព្រះគ្រីស្ទបានផ្ទុកអំពើបាប ដែលយើងរាល់គ្នាបានប្រព្រឹត្តនៅលើអង្គទ្រង់ ហើយសុគតជំនួសយើងរាល់គ្នា ។ បីថ្ងៃក្រោយមក ព្រះគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ដើម្បីបង្ហាញថា ទ្រង់មានអំណាចឈ្នះលើអំពើបាប និងសេចក្តីស្លាប់ ហើយការប្រកាសអះអាងថា ជាព្រះរបស់ព្រះអង្គ គឺជាការពិតមែន ។

# ដំណឹងល្អទី ២

## អ្នកអាចបានសង្គ្រោះដោយសារសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ

*អេភេសូរ ២:៨-៩ បានចែងថា “ [៨] ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះ ក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ [៩] ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន។ ”*

## សេចក្ដីជំនឿមានន័យថា *ការទុកចិត្ត*

***សំណួរ.*** *តើអ្នកត្រូវទុកចិត្តលើព្រះគ្រីស្ទដើម្បីអ្វី ?*
***ចម្លើយ.*** *អ្នកត្រូវពឹងផ្អែកលើទ្រង់តែមួយអង្គគត់ ដើម្បីអត់ទោសបាបនិងប្រទានជីវិតអស់កល្បជានិច្ចឲ្យដល់អ្នក ។*

ដូចជាការដែលអ្នកទុកចិត្តថា កៅអីអាចនឹងទ្រអ្នកបាន
ដោយមិនចាំបាច់ឲ្យអ្នកប្រឹងចំណាយកម្លាំងអ្នកផ្ទាល់ទេ
ដូច្នេះ អ្នកត្រូវតែទុកចិត្តលើព្រះយេស៊ូវគ្រីស្ទឲ្យនាំអ្នកចូលទៅ
នគរស្ថានសួគ៌ ដោយមិនត្រូវការពឹងផ្អែកលើ
កម្លាំងរបស់អ្នកផ្ទាល់ឡើយ ។



ប៉ុន្តែ អ្នកប្រហែលជានិយាយថា :

"ខ្ញុំជាអ្នកកាន់សាសនា"

"ខ្ញុំទៅព្រះវិហារ"

"ខ្ញុំជាមនុស្សល្អ"

"ខ្ញុំតែងជួយអ្នកក្រ"

"ខ្ញុំមិនដែលប្រព្រឹត្តអំពើណាអាក្រក់ខ្លាំងទេ"

ការទាំងអស់នេះពិតជាល្អមែន ប៉ុន្តែ ការរស់នៅបានល្អ
ការទៅព្រះវិហាររាល់សប្តាហ៍ ការជួយអ្នកក្រីក្រ ឬក៏ការល្អដទៃទៀត
ដែលអ្នកអាចធ្វើ មិនអាចនាំអ្នកចូលទៅនគរស្ថានសួគ៌បានទេ ។
អ្នកត្រូវទុកចិត្តលើព្រះយេស៊ូវគ្រីស្ទតែមួយអង្គគត់ នោះព្រះ
នឹងប្រទានឲ្យនូវអំណោយទានជាជីវិតអស់កល្បជានិច្ចដល់អ្នក ។

## ឥឡូវនេះ តើមានអ្វីដែលរារាំងអ្នកមិនឲ្យដាក់ការទុកចិត្តលើអង្គព្រះយេស៊ូវគ្រីស្ទឬទេ ?

១. ____________________

២. ____________________

៣. ____________________

៤. ____________________

*សូមគិតពិចារណាឲ្យបានហ្មត់ចត់ គ្មានការអ្វីផ្សេងទៀតដែលសំខាន់ជាងការដែលអ្នកត្រូវទុកចិត្តលើព្រះគ្រីស្ទទេ ។*

*តើអ្នកចង់ទូលថ្វាយព្រះថា អ្នកសំរេចថ្វាយ ការទុកចិត្តលើព្រះអម្ចាស់យេស៊ូវគ្រីស្ទធ្វើជាព្រះអង្គសង្គ្រោះអ្នកឬទេ ? បើសិនជា អ្នកចង់ ហេតុអ្វីមិនអធិស្ឋានឥឡូវនេះ ហើយទូលថ្វាយដល់ព្រះថា អ្នកកំពុងទុកចិត្តលើព្រះរាជបុត្រាទ្រង់ ?*

# សូមចងចាំ !

មិនមែនការអធិស្ឋាន សង្គ្រោះអ្នកទេ ។ គឺជាការទុកចិត្តលើអង្គព្រះយេស៊ូវគ្រីស្ទដែលនាំឲ្យអ្នកបានទទួលសេចក្ដីសង្គ្រោះ ។ ការអធិស្ឋានគ្រាន់តែជាការបង្ហាញពីការដែលអ្នកទូលថ្វាយព្រះថា អ្នកកំពុងតែធ្វើអ្វីតែប៉ុណ្ណោះ ។

*ព្រះអង្គអើយ ! ទូលបង្គំដឹងថា ទូលបង្គំជាមនុស្សមានបាប ។ ទូលបង្គំដឹងថា អំពើបាបទូលបង្គំ សមនឹងទទួលនូវការដាក់ទោស ។ ទូលបង្គំជឿថា ព្រះគ្រីស្ទបានសុគតជំនួសបាបទូលបង្គំ ហើយរស់ពីសុគតឡើងវិញពិត ។ ទូលបង្គំ សូមទុកចិត្តលើព្រះយេស៊ូវគ្រីស្ទតែមួយអង្គគត់ ធ្វើជាព្រះអង្គសង្គ្រោះរបស់ទូលបង្គំ ។ អរគុណព្រះអង្គដែលបានអត់ទោសបាបនិងប្រទានជីវិតអស់កល្បជានិច្ចឲ្យទូលបង្គំ ។ ទូលបង្គំអធិស្ឋានសូម ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ។ អាម៉ែន*



# តើការអ្វីដែលទើបតែបានកើតឡើង ?

*យ៉ូហាន ៥:២៤ បានបញ្ជាក់ថា “ អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ ”*

- *តើអ្នកបាន “ ស្តាប់ ” ព្រះបន្ទូលព្រះឬទេ ?*
- *តើអ្នកបាន “ ជឿ ” អ្វីដែលព្រះទ្រង់មានបន្ទូល ហើយទុកចិត្តព្រះគ្រីស្ទឲ្យធ្វើជាព្រះអង្គសង្គ្រោះរបស់អ្នកឬទេ ?*
- *តើ “ មានជីវិតដ៏នៅអស់កល្បជានិច្ច ” មានន័យថា នៅពេលខាងមុខ ឬ ពេលឥឡូវនេះ ?*
- *តើគម្ពីរចែងថា “ មិនដែលត្រូវជំនុំជំរះឡើយ ” ឬក៏ ប្រហែលនឹងមិនត្រូវជំនុំជំរះ ?*
- *តើគម្ពីរចែងថា “ បានកន្លងហួសពីសេចក្តីស្លាប់ ” ឬក៏ នឹងកន្លងហួស ?*

**ជីវិតអស់កល្បជានិច្ចពឹងផ្អែកលើសេចក្តីពិត មិនមែនលើអារម្មណ៍ទេ**

*ទន្ទេញខគម្ពីរ យ៉ូហាន ៥:២៤ ឲ្យបានចាំនៅថ្ងៃនេះ ។*

# ឥឡូវនេះ តើអ្នកត្រូវធ្វើអ្វី ?

រក្សាការទុកចិត្តលើព្រះគ្រីស្ទ ធ្វើជាផ្លូវតែមួយគត់សំរាប់អ្នក ដើម្បីចូលទៅស្ថានសួគ៌ ខាងក្រោមនេះ ជាវិធីក្នុងការជួយអ្នកឲ្យចំរើនលូតលាស់ការប្រកបទាក់ទងរបស់អ្នកជាមួយព្រះ ។

» ទូលថ្វាយព្រះនូវអ្វីដែលអ្នកមានក្នុងគំនិតតាមរយៈការអធិស្ឋាន ( ភីលីព ៤:៦,៧ )

» អានព្រះគម្ពីររាល់ថ្ងៃ ដើម្បីឲ្យបានស្គាល់ទ្រង់ឲ្យកាន់តែច្បាស់ និងរៀនអំពីទ្រង់ ( ២ ធីម៉ូថេ ៣:១៦-១៧ ) ដោយចាប់ផ្តើមអានពីគម្ពីរភីលីព ។

» ចូលរួមថ្វាយបង្គំព្រះជាមួយក្រុមជំនុំក្នុងតំបន់ដែលអ្នករស់នៅ ( ហេព្រើរ ១០:២៤-២៥ )

» ប្រកាសប្រាប់អ្នកដទៃអំពីព្រះយេស៊ូវគ្រីស្ទ ( ម៉ាថាយ ៤:១៩ )

បើអ្នកឃើញថាកូនសៀវភៅនេះមានប្រយោជន៍
សូមយកទៅចែកចាយបន្តដល់អ្នកឯទៀត ។
ប្រសិនបើ អ្នកមានសំណួរទៅថ្ងៃក្រោយ អំពីអ្វី
ដែលសរសេរក្នុងកូនសៀវភៅនេះ, សូមទាក់ទង :

Evantell

The Gospel. Clear and Simple.

p.o. box 741417 | dallas, tx 75374
www.evantell.org | 800.947.7359
© 2007 evantell, inc.

Khmer
TRMKM001